# កុំផ្អាប់គំនិតល្អ

បើមានគំនិតល្អសំរាប់ប្រយោជន៍ជាតិ កុំនាំគ្នាផ្អាប់វា ដោយយល់ឃើញថា វាជាយុទ្ធសាស្ត្រសម្ងាត់ ព្រោះថា អ្វីដែលជាការសម្ងាត់ វាតែងពង្រាក់ខ្លឹមសារ នៃគំនិត។ គំនិតល្អ ត្រូវការព្រលាន (espace) នៃស្មារតីសាធារណៈ ដ៏ធំទូលាយ សំរាប់ឱ្យវារីកស្រស់ស្រាយដោយសេរី។ គំនិតល្អ ជាប្រយោជន៍ជាតិ វាគ្មានលក្ខណៈ ជាគំនិតយុទ្ធសាស្ត្រនោះឡើយ ព្រោះសារជាតិ ជាធម្មជាតិរបស់វា ជាព្រលឹងជាតិ ដែលវាត្រាំនៅក្នុងស្មារតីរបស់ប្រជាជាតិរួចមកហើយ គ្រាន់តែវាចាំឱកាសល្អនឹងពង្រីក ជាភាពសប្បាយរីករាយនៅក្នុងចិត្តរបស់ប្រជាពលរដ្ឋ។ ដូច្នេះ បើធ្វើឱ្យវាទៅជាការសម្ងាត់ ពិតហើយ ! នឹងធ្វើឱ្យវាថមថយនៅក្នុងព្រលានថប់ ដែលនាំឱ្យវាទៅជាគំនិតឡើងរឹង ក្លាយជាគំនិតឥតប្រយោជន៍ ឬ មិនស្របឱកាសនៅពេលយកវាមកអនុវត្ត។ នយ:ជន (អ្នកនយោបាយ) ទូទៅដឹងច្បាស់ពីបញ្ហានេះ ហើយអ្នកខ្លះ គាត់មាន អាកប្បកិរិយាអវិជ្ជមាន ដូច្នេះគាត់ត្រូវតែលាក់គំនិតល្អសំរាប់ជាតិ ដើម្បីស្វែងរកអត្តប្រយោជន៍។ តែអ្នកខ្លះទៀត យល់ដឹងពី ការមានវិសាលភាពឥតកំណត់ នៃគំនិតល្អ សំរាប់ជាតិនេះ នៅក្នុងគំនិតមហាជន ដូច្នេះគាត់មិនខ្លាចផ្សាយ ជាសាធារណៈគ្មានការកក់ ដើម្បី បង្កើតថាមពលជាតិ។ គំរោង នៃមាតុភូមិនិវត្តន៍របស់លោក សម រង្ស៊ីគួរមានតម្លាភាពគ្រប់ជ្រុង ព្រោះគាត់ត្រូវគិតថា គាត់មិនមែនជាជនលួចលាក់។ ប្រសិនបើគាត់ត្រូវបានគេចាប់ខ្លួន តើនោះវាមានអ្វីជាការចម្លែកនៅក្នុងរបបផ្តាច់ការ ?